ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...២២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើបំណាស់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ នូវទីតាំងដីសំរាប់ការសាងសង់អគារប៉ុស្តិ៍ព្រំដែននៅច្រកព្រំដែនព្រែកចាក/លក នៅខេត្តកំពត

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ ០២/នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១**

ត្រូវបានកំណត់បរិវេណដី សំរាប់ធ្វើការសាងសង់អគារប៉ុស្តិ៍ត្រួតពិនិត្យព្រំដែននៅច្រកព្រំដែនព្រែកចាក/លក ដែលមានទីតាំងស្ថិតនៅក្នុងភូមិថ្កូវ ឃុំឬស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ។

**មាត្រា ២**

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុបប្រមាណ ៤ ហិកតា ជាប្រភេទដីដែលមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ហើយមានទីតាំងស្ថិតនៅក្នុងភូមិថ្កូវ ឃុំឬស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥, មាត្រា ១៦, មាត្រា ១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ និងមាននិយាមការដូចខាងក្រោម:

| No. | Northing | Easting |
|---|---|---|
| A | 1152674.131 | 440050.580 |
| B | 1152710.072 | 440026.595 |
| C | 1152749.356 | 440086.578 |
| D | 1152804.765 | 440049.506 |
| E | 1152929.861 | 440240.587 |
| F | 1152799.266 | 440327.740 |
| G | 1152683.628 | 440151.106 |

**មាត្រា ៣**

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ការផ្ទេរកម្មសិទ្ធិ ឬផ្ទេរសិទ្ធិកាន់កាប់ដី ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់នៃអចលនវត្ថុទាំងឡាយតាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលស្ថិតនៅក្នុងបរិវេណដីបង្អួកដូចបានពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតឱ្យសាងសង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការផ្ទេរកម្មសិទ្ធិសម្រាប់បំរើផលប្រយោជន៍សាធារណៈ ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងត្រូវទទួលទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ។

**មាត្រា ៤**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃដីឡូត៍ ក្នុងបរិវេណដែលនឹងត្រូវផ្ទេរប្រគល់ជូនរដ្ឋដើម្បីជាប្រយោជន៍សាធារណៈ នឹងទទួលបាននូវការទូទាត់សំណងពីគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគំរោងការសាងសង់អគារប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនខាងលើនេះ ។

**មាត្រា ៥**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធព្រមទាំង អភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៦**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមលោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ